# សៀវភៅមគ្គុទេសក៍

## ដំណើរការស្នើសុំប្រតិបត្តិការលើវិស័យប្រៃសណីយ៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន តាមរយៈប្រព័ន្ធ E-registration



**អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន**

នាយកដ្ឋានកម្មវិធីកុំព្យូទ័រនិងមាតិកាព័ត៌មាន

# មាតិកា

ផ្នែកទី១៖ ព័ត៌មានទូទៅ........................................................................................................១
១.១ ហេតុអ្វីត្រូវចុះបញ្ជីស្នើសុំធ្វើប្រតិបត្តិការ?.................................................................................១
១.២ នីតិវិធីនៃការចុះបញ្ជីស្នើសុំធ្វើប្រតិបត្តិការតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន.................................១
១.៣ ឯកសារភ្ជាប់.........................................................................................................២
ផ្នែកទី២៖ ចុះបញ្ជីស្នើសុំធ្វើប្រតិបត្តិការតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន.....................................................៣
២.១ ដំណើរការចុះបញ្ជីស្នើសុំធ្វើប្រតិបត្តិការតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន...................................៣
២.១.១ ការ Log in ចូលគេហទំព័រផតថល.....................................................................៣
២.១.២ ដំណើរការចុះបញ្ជីស្នើសុំធ្វើប្រតិបត្តិការតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន...........................៥
២.១.៣ ដំណើរការបង់ប្រាក់.......................................................................................១១
២.១.៤ ពិនិត្យស្ថានភាព និងទទួលសារជូនដំណឹងក្នុងដំណាក់កាលនីមួយៗ..........................១២
ជំនួយបន្ថែម.......................................................................................................................១៧

# ផ្នែកទី១៖ ព័ត៌មានទូទៅ

## ១.១ ហេតុអ្វីត្រូវចុះបញ្ជីស្នើសុំធ្វើប្រតិបត្តិការ?




## ១.២ នីតិវិធីនៃការចុះបញ្ជីស្នើសុំធ្វើប្រតិបត្តិការតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន



សម្រាប់ការស្នើសុំធ្វើប្រតិបត្តិការតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីនេះ អ្នកគ្រាន់តែចូលទៅកាន់ផតថលរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រួចប្រើ CamDigiKey ដើម្បីចូលទៅក្នុងប្រព័ន្ធកម្មវិធី បន្ទាប់មកធ្វើការជ្រើសរើសប្រភេទប្រតិបត្តិការដែលត្រូវស្នើសុំ ដោយបញ្ចូលព័ត៌មានម្ចាស់ពាក្យសុំ និងព័ត៌មានក្រុមហ៊ុន ដែលព័ត៌មានទាំងពីរនេះត្រូវបានទាញយកមកបំពេញដោយស្វ័យប្រវត្តិតាមរយៈថ្នាលព័ត៌មាន CamDX រីឯអ្នកស្នើសុំគ្រាន់តែបំពេញបន្ថែមព័ត៌មានចាំបាច់មួយចំនួនតូចប៉ុណ្ណោះ។ បន្ទាប់ពីពិនិត្យផ្ទៀងផ្ទាត់ត្រឹមត្រូវរួចហើយ អ្នកស្នើសុំអាចដាក់ពាក្យសុំ និងធ្វើការបង់ប្រាក់តាមអនឡាញជាមួយធនាគារដៃគូរដែលរួមមាន ធនាគារកាណាឌីយ៉ា ធនាគារវឌ្ឍនៈអាស៊ី (ABA) និងធនាគាអេស៊ីលីដា (ACLEDA)។ បន្ទាប់ពីទទួលបានការឯកភាពពីមន្ត្រី ប្រព័ន្ធកម្មវិធីនឹងបញ្ជូនសារទៅអ្នកស្នើសុំដើម្បីធ្វើការបង់ប្រាក់កម្រៃប្រតិបត្តិការដោយយោងទៅតាមអត្រាតម្លៃដែលមានចែងក្នុងសេចក្តីប្រកាសរួមលេខ៤៩៨ សហវ.ប្រក តំណភ្ជាប់នៃសេចក្តីប្រកាស។

បន្ទាប់ពីបង់ប្រាក់រួចរាល់អ្នកស្នើសុំនឹងទទួលបានលិខិតអនុញ្ញាតឬវិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ក្នុងទម្រង់ឌីជីថល តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

**កំណត់ចំណាំ៖** ចំពោះតម្លៃនៃសេវាកម្ម ***សូមចុចទីនេះ*** ដើម្បីធ្វើការត្រួតពិនិត្យលម្អិត។

## ១.៣ ឯកសារភ្ជាប់



- រាល់ឯកសារភ្ជាប់ទាំងអស់ត្រូវស្កិតក្នុងទម្រង់ PDF ដែលស្កេនពីច្បាប់ដើម ហើយមានគុណភាពល្អ។
- សូមបញ្ជាក់ថា ប្រសិនបើលោកអ្នកមិនផ្តល់ឯកសារឬ ព័ត៌មានគ្រប់គ្រាន់ និងច្បាស់លាស់ក្នុងពេលលោកអ្នកស្នើសុំតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់យើង លោកអ្នកអាចនឹងប្រឈមការបដិសេធលើសំណើសុំ។
- ក្នុងករណីនេះ រាល់ការចំណាយដែលបានធ្វើឡើងលើប្រព័ន្ធនេះ នឹងមិនមានការធានាចំពោះការប្រគល់ប្រាក់ជូនវិញនោះទេ។

# ផ្នែកទី២៖ ចុះបញ្ជីស្នើសុំធ្វើប្រតិបត្តិការតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

## ២.១ ដំណើរការចុះបញ្ជីស្នើសុំធ្វើប្រតិបត្តិការតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ដំណើរការចុះបញ្ជីស្នើសុំធ្វើប្រតិបត្តិការតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចែកចេញជា ៧ ជំហានធំៗ៖



## ២.១.១ ការ Log in ចូលគេហទំព័រផតថល

ក) ចូលទៅតំណភ្ជាប់ដែលមានអាសយដ្ឋាន https://service.mptc.gov.kh/




ខ) ចុចប៊ូតុង ទាញយក QR Code

គ) ស្កេន QR Code ដែលអ្នកបានឃើញជាមួយនឹង CamDigiKey App នៅលើទូរស័ព្ទដៃរបស់លោកអ្នក

ឃ) បញ្ចូលលេខកូដផ្ទាល់ខ្លួន ៦ខ្ទង់ដែលលោកអ្នកបានបង្កើតក្នុង CamDigiKey App ។ ប្រព័ន្ធកម្មវិធីនឹងអោយលោកអ្នកចូលដោយស្វ័យប្រវត្តិប្រសិនបើលេខកូដត្រឹមត្រូវ។



២.១.២ ដំណើរការចុះបញ្ជីស្នើសុំធ្វើប្រតិបត្តិការតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ក) ជ្រើសរើស សេវាបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬ សេវាប្រៃសណីយ៍




ខ) ជ្រើសរើស លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ



គ) ជ្រើសរើសប្រតិបត្តិការ (អាចរើសយកលើសពីមួយ) រួចចុចប៊ូតុងបន្ទាប់



ឃ) ជ្រើសរើសក្រុមហ៊ុន និងបំពេញព័ត៌មានដែលនៅខ្វះ បន្ទាប់មកចុចប៊ូតុងបន្ទាប់



**សំគាល់៖** ព័ត៌មានក្រុមហ៊ុនត្រូវបានបំពេញអោយដោយស្វ័យប្រវត្តិ បន្ទាប់ពីបានជ្រើសរើសឈ្មោះក្រុមហ៊ុន អាស្រ័យទៅតាមទិន្នន័យដែលទាញយកបានតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន CamDX ។

ង) បំពេញព័ត៌មានអ្នកស្នើសុំដែលនៅខ្វះ បន្ទាប់មកចុចប៊ូតុងបន្ទាប់




**សំគាល់៖** ព័ត៌មានម្ចាស់ពាក្យសុំត្រូវបានបំពេញអោយដោយស្វ័យប្រវត្តិ អាស្រ័យទៅតាមទិន្នន័យដែលទាញយកបានតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន CamDX ។

ច) បញ្ចូលឯកសារយោងជាទម្រង់ PDF បន្ទាប់មកចុចប៊ូតុងបន្ទាប់




**សំគាល់៖** ឯកសារយោងមួយចំនួនត្រូវបានបំពេញអោយដោយស្វ័យប្រវត្តិ អាស្រ័យទៅតាមទិន្នន័យដែលទាញយកបានតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន CamDX ។

ឆ) ពិនិត្យនិងផ្ទៀងផ្ទាត់ព័ត៌មានឡើងវិញ បន្ទាប់មកចុចប៊ូតុងបញ្ជូន



**សំគាល់៖** ប្រសិនបើពិនិត្យទៅឃើញមានខ្វះចន្លោះឬព័ត៌មានមិនត្រឹមត្រូវ លោកអ្នកអាចត្រលប់ថយក្រោយដើម្បីធ្វើការកែតម្រូវនិងបំពេញបន្ថែមបានដោយគ្រាន់តែចុចប៊ូតុង ***ថយក្រោយ*** ។ ប្រសិនបើពិនិត្យទៅឃើញថាត្រឹមត្រូវ

អស់ហើយសូមចុចប៊ូតុង ***បញ្ជូន*** បន្ទាប់មកប្រព័ន្ធកម្មវិធីនឹងនាំលោកអ្នកទៅដល់ផ្ទាំងបង់ប្រាក់។

២.១.៣ ដំណើរការបង់ប្រាក់




ក) ជ្រើសរើសធនាគារដៃគូរដែលរួមមាន៖ ABA, CANADIA, ACLEDA ដើម្បីបង់ប្រាក់តាមអនឡាញ លោកអ្នកក៏អាចបង់ប្រាក់ដោយប្រើកាត VISA ឬ Master បានផងដែរ ប៉ុន្តែអាចនឹងត្រូវមានការបង់ថ្លៃសេវាបន្ថែម (Additional Charge)។

ខ) ប្រសិនបើចង់បង់ជាសាច់ប្រាក់ ឬមូលប្បទានប័ត្រ តម្រូវអោយចុចលើប៊ូតុង ***បោះពុម្ព*** រួចយកមកបង់ដោយផ្ទាល់នៅបេឡាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

គ) បន្ទាប់ពីបង់ប្រាក់រួចរាល់ ដំណាក់កាលនៃការដាក់ពាក្យសុំត្រូវបានបញ្ចប់ និងត្រូវរង់ចាំការសម្រេចពីមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

### ២.១.៤ ពិនិត្យស្ថានភាព និងទទួលសារជូនដំណឹងក្នុងដំណាក់កាលនីមួយៗ

ក) បន្ទាប់ពី Log in ចូលទំព័រផេតថលរួច ចុចលើ **“ពាក្យសុំ (បានដាក់ពាក្យ)”** ដើម្បីបើកតារាងពាក្យសុំដែលបានដាក់ស្នើរួចហើយ។



ខ) ចុចលើពាក្យស្នើសុំ (បានដាក់ពាក្យ) ដើម្បីមើលស្ថានភាពនិងព័ត៌មានលម្អិត



គ) ចុចលើ “ពាក្យសុំ(មានបញ្ហា)” ដើម្បីបើកតារាងពាក្យសុំដែលមានបញ្ហា




**សំគាល់៖** ពាក្យសុំមានបញ្ហា ត្រូវបានចែកចេញជាពីរ គឺ “បានបញ្ជូនត្រលប់”និង “បានបដិសេធ”។

- បានបញ្ជូនត្រលប់៖ មានន័យថាពាក្យសុំត្រូវបានបញ្ជូនត្រលប់មកពីមន្ត្រីវិញបន្ទាប់ពីពិនិត្យទៅឃើញថាព័ត៌មានមិនគ្រប់គ្រាន់ដែលតម្រូវអោយបំពេញបន្ថែមដើម្បីអាចដាក់ស្នើបន្តទៀតបាន។
- បានបដិសេធ៖ មានន័យថាពាក្យសុំត្រូវបានបដិសេធដោយមន្ត្រីមានសមត្ថកិច្ច ក្នុងករណីនេះអ្នកមិនអាចដាក់ស្នើសុំបន្តទៀតបានទេ។

ឃ) ចុចលើ “បានបញ្ជូនត្រលប់” រួចចុចលើពាក្យសុំណាមួយ ដើម្បីបើកមើលព័ត៌មានលម្អិត






ង) ចុចលើ "បានបដិសេធ" រួចចុចលើពាក្យសុំណាមួយ ដើម្បីបើកមើលព័ត៌មានលម្អិត





# ជំនួយបន្ថែម

ប្រព័ន្ធផ្តល់សេវាសាធារណៈឌីជីថល

អគារលេខ១៣ មហាវិថីព្រះមុន្នីវង្ស

https://service.mptc.gov.kh/

070 972 707 | 023 724 911 (សេវាប្រៃសណីយ៍)

023 723 083 (សេវាបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន )

e-registration@mptc.gov.kh

ជជែកផ្ទាល់នៅលើគេហទំព័រ

https://www.facebook.com/www.mptc.gov.kh

https://www.youtube.com/c/MPTCMedia/featured